# ធម្មទេសនារបស់លោកអភិបាលអូលីវីយេ
# អភិបូជានៅអរិយក្សត្រ
# ថ្ងៃទី៣០ ធ្នូ ២០១៧
## *ក្រុមគ្រួសារជាមូលដ្ឋាននៃសង្គម*

អត្ថបទទី១៖ ១យហ ២,១២-១៧
ដំណឹងល្អ៖លក ២,៣៦-៤០

បងប្អូនជាទីស្រឡាញ់!

នៅក្នុងឆ្នាំនេះ យើងទទួលជីវិតថ្មីតាមរយៈព្រះយេស៊ូ ដែលព្រះពន្លឺ ដែលជាព្រះគ្រីស្ត។ ជាពិសេសថ្ងៃនេះ យើងសម្លឹងមើលព្រះនាងម៉ារី ដែលព្រះជាម្ចាស់បានជ្រើសរើសដើម្បីធ្វើជាមាតារបស់ព្រះអង្គ។ ព្រះនាងម៉ារី ឥតមានការប្រព្រឹត្តអ្វីអស្ចារ្យប៉ុន្មានទេ ព្រះនាងម៉ារីបានទុកអ្វីដែលគាត់បានឃើញ អ្វីដែលគាត់បានលឺនៅក្នុងដួងចិត្តរបស់គាត់។ ព្រះនាងម៉ារី កំពុងសម្លឹងមើលការអស្ចារ្យផ្ទាល់ភ្នែករបស់ព្រះនាង គឺព្រះយេស៊ូដែលជាព្រះជាម្ចាស់បានប្រសូតពីផ្ទៃពោះរបស់ព្រះនាង ដោយសារព្រះជាម្ចាស់បានជ្រើសរើសមនុស្សម្នាក់ យុវនារីម្នាក់ ដែលជាយុវនារីសាមញ្ញធម្មតា ដើម្បីទៅជាមាតារបស់ព្រះជាម្ចាស់។ ចាប់ពីពេលនេះតទៅយើងអាចនិយាយថា ពិភពលោករបស់យើងមិនដូចពីមុនទេ ពិភពលោករបស់យើងទៅជាពិភពថ្មី ពីព្រះជាម្ចាស់បានបង្កើតពិភពលោកពីដើមរៀងមក មនុស្សយើងបានណែនាំឲ្យពិភពរបស់យើង មានអំពើសាហាវ បញ្ហាយ៉ាងច្រើន មានអ្វីៗទាំងអស់ដែលណែនាំពីព្រះជាម្ចាស់ពិបាកព្រះហឫទ័យ។ ប៉ុន្តែយប់បុណ្យព្រះយេស៊ូប្រសូត ព្រះជាម្ចាស់បានសំរេចចិត្តហើយ ពេលនេះណែនាំឲ្យមនុស្សចេះផ្សះផ្សារគ្នា ដើម្បីទៅជាមនុស្សលោកថ្មី។ នៅយប់ព្រះយេស៊ូប្រសូតរហូតមកដល់ពេលនេះ យើងបានស្តាប់រឿងដ៏អស្ចារ្យគឺព្រះយេស៊ូប្រសូត បើសិនជាបងប្អូនអង្គុយនៅមុខរោងព្រះយេស៊ូ យើងអាចមើលឃើញសង្គមថ្មីដែលព្រះជាម្ចាស់ចង់បង្កើត កំពុងតែកើតឡើងពិតមែន។ សង្គមថ្មីនេះចាប់ផ្តើមដោយក្រុមគ្រួសារដ៏វិសុទ្ធ យើងមានព្រះនាងម៉ារី យើងមានលោកយ៉ូសែប យើងមានព្រះកុមារយេស៊ូ។ សង្គមនីមួយៗ ចាប់ផ្តើមដោយក្រុមគ្រួសារនីមួយៗ នៅពេលក្រុមគ្រួសារមួយមានសេចក្តីសុខសាន្ត សង្គមយើងមានសេចក្តីសុខសាន្តដែរ។ ព្រះសហគមន៍នៅយប់បុណ្យព្រះយេស៊ូប្រសូត ឲ្យយើងសម្លឹងមើលសង្គមថ្មីតាមរយៈក្រុមគ្រួសារ។ មានលោកយ៉ូសែបថែរក្សាព្រះនាងម៉ារី ដោយរកកន្លែងមួយយ៉ាងសមរម ដើម្បីឲ្យព្រះនាងសំរាលកូនបាន។ មានព្រះនាងម៉ារី ដែលកំពុងបីឱរសដែលកើតថ្មីៗ នៅក្នុងសេចក្តីសុខសាន្ត។ មានព្រះ

យេស៊ូដែលនៅក្រោមក្ដីស្រឡាញ់របស់ឪពុកម្ដាយគាត់។ នេះជាគ្រួសារដ៏សុខសាន្ត ដែលណែនាំឲ្យគ្រួសារនីមួយៗរបស់យើង រកឃើញសេចក្ដីសុខសាន្តដើម្បីបង្កើតសង្គមមួយដ៏សុខសាន្ត។

យើងមានក្រុមគ្រូគង្វៀល ជាមនុស្សដែលសង្គមមិនសូវពេញចិត្តប៉ុន្មានទេ ជាក្រុមមួយដែលរស់នៅដោយឡែកពីភូមិនីមួយៗ គេដើរពីភូមិមួយទៅភូមិនៅពេលយប់ឡើងគេប្រមូលហ្វូងចៀមរបស់គេ ដើម្បីដេកនៅក្រៅភូមិ ជាទូទៅប្រជាជនមិនសូវពេញចិត្តប៉ុន្មានទេ ជាមនុស្សដែលនៅក្រៅសង្គមម្យ៉ាង។ ប៉ុន្តែអ្នកដែលទទួលដំណឹងមុនគេបង្អស់យប់នេះមានព្រះសង្គ្រោះដែលប្រសូតហើយ គឺក្រុមគ្រូគង្វាលដែលនៅខាងក្រៅសង្គម ដោយសារព្រះយេស៊ូចូលទៅសង្គមមុនគេបង្អស់។ សង្គមថ្មីមិនមែនសង្គមដែលមានព្រំដែន សង្គមថ្មីដែលព្រះជាម្ចាស់កំពុងបង្កើតនៅយប់យប់បុណ្យព្រះយេស៊ូប្រសូត ជាសង្គមដែលគ្មានព្រំដែន ដែលទទួលស្វាគមន៍មនុស្សទាំងអស់។ សង្គមថ្មីដែលព្រះជាម្ចាស់បង្កើតនៅយប់បុណ្យព្រះយេស៊ូប្រសូត ជាសង្គមមួយដែលស្វាគមន៍មនុស្សទាំងអស់ ដោយសារមនុស្សទាំងអស់ ជាតំណាងនៃព្រះជាម្ចាស់ មនុស្សទាំងអស់ជាបុត្រធីតាបានជ្រើស មនុស្សទាំងអស់ដែលបានប្រកាសថា **អាបា! ឱព្រះបិតាអើយ** នេះជាសង្គមដែលព្រះជាម្ចាស់ចង់ឲ្យមាន។ ជាគ្រូគង្វៀល ដែលចេញពីរោងព្រះយេស៊ូប្រសូតហើយ ចូលទៅក្នុងភូមិដើម្បីប្រាប់ប្រជាជនព្រះសង្គ្រោះបានប្រសូតហើយ។

ដូច្នេះក្រុមទីពីរដែលមកថ្វាយបង្គំព្រះយេស៊ូ គឺប្រជាជនទាំងអស់នៅក្នុងភូមិគេមកមើលមានអ្វីកើតឡើងនៅក្នុងក្រោលគោហ្នឹង នេះជាប្រជាជនធម្មតា ដែលរស់នៅធម្មតានៅក្នុងសង្គមធម្មតា ប៉ុន្តែយប់ហ្នឹងទោះអ្នកដែលកាន់សាសនាយ៉ូដាក៏ដោយ គេទៅមើលព្រះសង្គ្រោះ ដែលប្រជារាស្ត្រអ៊ីស្រាអែលទន្ទឹងរង់ចាំពីដើមរៀងមក។ សង្គមដែលព្រះជាម្ចាស់ចង់បង្កើត ជាសង្គមមួយដែលមនុស្សទាំងអស់អាចជួបជុំគ្នាជាគ្រួសារមួយ ដោយសារនៅពេលប្រជាជនចាប់ផ្ដើមចេញពីផ្ទះនីមួយៗ ដើម្បីទៅថ្វាយបង្គំព្រះយេស៊ូ និងសួរសុខទុក្ខព្រះនាងម៉ារីនិងលោកយ៉ូសែប ជាក្រុមគ្រួសារដែលមិនស្គាល់គ្នាពីមុន ប៉ុន្តែនៅពេលដែលគេថ្វាយបង្គំរួមគ្នា គេទៅជាក្រុមគ្រួសារតែមួយ ទៅជាបងប្អូនគ្នា ដែលថ្វាយបង្គំរួមជាមួយគ្នា ដែលច្រៀងកោតសរសើរព្រះជាម្ចាស់រួមជាមួយគ្នា ដែលចេះរកឃើញអត្ថន័យនៃជីវិតថ្មី ដោយសារជីវិតរបស់យើងមិនតែរវីរវល់រកស៊ី ប៉ុន្តែជីវិតរបស់យើងមិនគេបង្អស់រវីរ

រស់ដើម្បីថ្វាយបង្គំ និងកោតសរសើរព្រះជាម្ចាស់។ មុនគេបង្អស់ យើងជាគ្រីស្តបរិសទ័យើង ត្រូវតែថ្វាយបង្គំ មុនធ្វើបុណ្យ មុនជួយគេ មុនគិតអំពីផ្ទាល់ខ្លួន យើងគិតដល់ព្រះជាម្ចាស់ជាអតិភាពនៃជីវិតរបស់យើង។ យប់ដ៏សុខសាន្ត នៃបុណ្យព្រះយេស៊ូប្រសូតគឺសង្គមថ្មីនេះ ជាសង្គមដែលចេះអង្គុយដើម្បីថ្វាយបង្គំរួមជាមួយគ្នា និងដើម្បីកោតសរសើរដល់ព្រះជាម្ចាស់ទៅជាអតិភាពនៃជីវិតដោយសារមានតែព្រះជាម្ចាស់ ដែលអាចបំភ្លឺជីវិតរបស់យើង និងប្រទានសេចក្តីសុខសាន្តដ៏ស្ថិតស្ថេរ អំណរសប្បាយដ៏ស្ថិតស្ថេរ។ អំណរសប្បាយដែលឈ្នះគ្រប់ភាពងងឹត និងទុក្ខលំបាក ឧបស័គ្គដែលយើងអាចជួបនៅក្នុងជីវិតរបស់យើងបាន។

ក្រុមទីបី ដែលទៅថ្វាយបង្គំព្រះយេស៊ូ គឺក្រុមហោរាចារ្យ ជាតំណាងនៃមនុស្សឈ្លៀសវៃ មនុស្សដែលមានប្រាជ្ញា មនុស្សដែលមានចំណេះដឹងយ៉ាងខ្ពស់ មនុស្សដែលមានទ្រព្យសម្បត្តិច្រើន មនុស្សដែលមានកម្លាំងមានអំណាច មានឋានៈនៅក្នុងសង្គមទាំងមូល។ អ្នកនោះគេមកថ្វាយបង្គំព្រះយេស៊ូ នៅក្រោលគោដែលអត់មានកំរាលក្រហម ដើម្បីទទួលស្វាគមន៍គេ ដោយអត់មានកង្ហា និងម៉ាស៊ីនត្រជាក់ដើម្បីឲ្យគេស្រួល ដើម្បីទទួលស្វាគមន៍គេ គេដូចគ្រូគង្វៀល គេដូចប្រជាជនទាំងឡាយ ហោរាចារ្យបានទៅថ្វាយបង្គំព្រះយេស៊ូនៅក្រោលគោដែរ។ ដោយសារសង្គមថ្មីដែលព្រះយ៉េស៊ូជាកំពុងបង្កើត ជាសង្គមមួយដែលយើងទាំងអស់យើងជាអ្នកធំ យើងជាអ្នកតូចតាច យើងអាចអង្គុយរួមតុជាមួយគ្នាបាន យើងមិនប្រកាន់ យើងអន់ចិត្តគ្នា។ សង្គមថ្មីដែលព្រះយ៉េស៊ូបង្កើត ជាសង្គមដែលមនុស្សទាំងអស់គ្រប់ជាតិសាសន៍ ដែលអង្គុយរួមគ្នា នេះអ្វីដែលព្រះជាម្ចាស់កំពុងបង្កើត។ សង្គមដ៏សុខសាន្ត ដែលរួមគ្នា យើងចេះស្តាប់គ្នា យល់ចិត្តគ្នា គោរពគ្នាទៅវិញទៅមក និងទទួលតួនាទីរបស់យើងដែលមាននៅនៅក្នុងសង្គមបច្ចុប្បន្ននេះ យើងជាអ្នកទទួលខុសត្រូវជាន់ខ្ពស់ ដោយស្តាប់អ្វីដែលខ្ញុំបាននិយាយដើម្បីអនុវត្តសម្រាប់សង្គមបច្ចុប្បន្ននេះ។ យើងជាគ្រីស្តបរិសទ័ ត្រូវតែណែនាំតាមសមត្ថភាពរបស់យើង ដោយធ្វើជាមេម្សៅនៅក្នុងសង្គមដើម្បីណែនាំឲ្យសង្គមថ្មីដែលព្រះយេស៊ូចង់បានកើតឡើង។

ក្រុមគ្រួសារជាមូលដ្ឋាននៃសង្គម មនុស្សខាងក្រៅដែលអាចចូលនៅក្នុងសង្គមបានប្រជាជនធម្មតាជាមួយអ្នកធំអាចអង្គុយជាមួយគ្នាបាន ដើម្បីនិយាយគ្នា ស្តាប់គ្នាសម្រុះសម្រួលគ្នា ដើម្បីរកឃើញផ្លូវដ៏សុខសាន្ត ដោយប្រសន្តិវិធីគ្រប់ពេលវេលា។ ប៉ុន្តែ

រឿងដែលខ្ញុំបាននិយាយ ជារឿងដែលយើងបានឃើញផ្ទាល់ភ្នែក យើងមានទុក្ខលំបាកដូច ពេលព្រះយេស៊ូប្រសូតហើយ ភ្លាមៗស្តេចហេរ៉ូដ ដែលបានចេញបញ្ជាឲ្យសម្លាប់កូនង៉ែត ក្រោយ២ឆ្នាំ ដោយសង្ឃឹមថានៅក្នុងនោះមានព្រះយេស៊ូដែរ តែសម្លាប់មិនបានមិនមែន ដោយសារគាត់ល្ងង់ទេ តែដោយសារភ្នែករបស់គាត់មើលមិនឃើញ។ ហោរាចារ្យនៅពេល គេឃើញផ្កាយនេះ គេយល់នៅក្នុងចិត្តរបស់ពួកគេ ដោយសារគេមានចិត្តទូលំទូលាយ ដើម្បីទទួលស្វាគមន៍ព្រះសង្គ្រោះដែលប្រសូតហើយ។ ស្តេចហេរ៉ូដអត់មានចិត្តទូលំ ទូលាយសោះ មើលមិនឃើញ ទទួលមិនបាន ទៅដល់កន្លែងក៏មិនបានទៀត សុខចិត្ត សម្លាប់កូនង៉ែតច្រើន ដូច្នេះយប់ដ៏សុខសាន្តនេះអំពើហិង្សាមិនទាន់ឈប់ទេ បានប្រព្រឹត្ត អំពើឃោរឃៅដល់កំពូល ជាឃាតករដោយបានសម្លាប់កូនដែលគ្មានបាបច្រើននាក់នៅ យប់នោះ នេះជាស្ថានភាពនៃសង្គមរបស់យើង។ ទោះបីយើងចង់បង្កើតសង្គមដ៏សុខសាន្ត ត្រូវតែមានមនុស្សមួយចំនួនដែលមិនចង់ទទួល ត្រូវតែមានមនុស្សដែលមានចិត្តចង្អៀត ចង្អល់ មានចិត្តច្រណែនដែលមានចិត្តលោភលន់ ដែលខិតខំសម្លាប់មនុស្សដែលគ្មានបាប សោះ ។

ម្សិលមិញនៅអេហ្ស៊ីប គេបានសម្លាប់មនុស្សកំពុងថ្វាយបង្គំបុណ្យព្រះយេស៊ូប្រសូត។ រហូតមកដល់សព្វថ្ងៃ គ្រប់ទីកន្លែងនៅមានស្តេចហេរ៉ូដ អំពើអាក្រក់នៅមិនទាន់ឈប់ ទៀត។ ហេតុនេះហើយទោះបីព្រះជាម្ចាស់ចង់បង្កើតសង្គមមួយដ៏សុខសាន្ត នៅពេលព្រះ នាងម៉ារីដែលពោរពេញដោយសប្បាយ នៅពេលលោកយ៉ូសែបពោរពេញដោយសេចក្តី សុខសាន្ត ប្រាំបីថ្ងៃក្រោយមកគេត្រូវការចេញធ្វើដំណើរគេចខ្លួន ទៅប្រទេសអេហ្ស៊ីប ដោយសារគេអត់មានសេចក្តីសុខក្នុងប្រទេសរបស់គេ។

យើងយប់បុណ្យព្រះយេស៊ូប្រសូត សម្តេចប៉ាប បាននិយាយខ្លាំងដល់ប្រទេសទាំងអស់ឲ្យ បើកទ្វារ ដើម្បីទទួលស្វាគមន៍ជនភៀសខ្លួន ដែលកំពុងចេញធ្វើដំណើរពីប្រទេសពួកគេ ដោយសារសង្គ្រាម ដោយអំពើហិង្សា ដោយសារការស្អប់គ្នា។ នៅប្រទេសប្រទេសភូមា ជិតមួយលាននាក់ ដែលបានចេញពីប្រទេសរបស់ពួកគេ ដោយសារគេអស់កន្លែង ដើម្បី ស្នាក់នៅដោយសេចក្តីសុខសាន្ត គេចខ្លួនដូចព្រះយេស៊ូព្រះនាងម៉ារីនិងលោកយ៉ូសែប។ យប់បុណ្យព្រះយេស៊ូប្រសូត នៅប្រទេសភូមាជាលើកទីមួយនៅក្នុងរយៈពេលហាសិបឆ្នាំ កន្លងមក ដែលគ្រីស្តបរិស័ទបានថ្វាយបង្គំព្រះយេស៊ូ ប្រារព្ធបុណ្យព្រះយេស៊ូប្រសូត ជាសា

សាធារណៈ។ ហាសិបឆ្នាំកន្លងមក គេបានឃើញធ្វើនៅក្នុងព្រះវិហារ ដោយបិទទ្វារ បិទរបងនៃព្រះវិហាររបស់គេ តែឆ្នាំនេះជាលើកទីមួយដែលគេមានសិទ្ធិ ដើម្បីហែរព្រះយេស៊ូប្រសូតនៅតាមផ្លូវជាសាធារណៈ។

ដូច្នេះយើងឃើញ ឥទ្ធិពលនៃព្រះពន្លឺត្រូវតែឈ្នះភាពងងឹត មួយរយៈសម្លាប់គេ មួយរយៈធ្វើបាបគេ មួយរយៈធ្វើឲ្យមនុស្សអស់សង្ឃឹមក្នុងជីវិត ជិះជាន់ សង្កត់សង្កិន ប៉ុន្តែមិនអាចឈ្នះរហូតនោះទេ ដោយសារពន្លឺឈ្នះជានិច្ច។ នៅយប់បុណ្យព្រះយេស៊ូប្រសូត យើងឃើញផ្កាលំភ្ញែកសង្គមថ្មីដែលកំពុងឡើងជាមួយក្រុមគ្រួសារដ៏វិសុទ្ធ ជាមួយមនុស្សដែលនៅក្រៅសង្គមបានចូលនៅក្នុងសង្គមបាន ប្រជាជនធម្មតាអង្គុយជាមួយអ្នកធំដោយអំណរសប្បាយ ដោយដឹងថាភាពងងឹតក៏នៅមានទៀត ភាវកម្មក៏នៅមានទៀត សង្គ្រាមណិងការស្អប់គ្នាក៏នៅមានទៀត ការឈ្លោះគ្នា អំពើហិង្សាក្នុងគ្រួសារ និងព្រះសហគមន៍ក៏មានទៀត ប៉ុន្តែចុងក្រោយបំផុតព្រះពន្លឺឈ្នះ។ នេះណែនាំឲ្យយើងចេញពីបុណ្យព្រះយេស៊ូប្រសូត ដើម្បីទៅដល់បុណ្យព្រះយេស៊ូសោយទិវង្គត និងព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ។ តាមពិតអាថ៌កំបាំងនេះជាអាថ៌កំបាំងតែមួយ ពីព្រះយេស៊ូប្រសូត រហូតដល់ព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ យើងមើលឃើញប្រវត្តិសាស្ត្រនៃការសង្គ្រោះទាំងអស់ ដែលត្រូវតែណែនាំជីវិតរបស់យើងចុងក្រោយបំផុត ទោះបីមានទុក្ខលំបាកនៅលើផែនដីនេះ តែរកឃើញសេចក្តីសុខនៅស្ថានបរមសុខ នេះជាការអស្ចារ្យនៃព្រះយេស៊ូបានចាប់កំណើតជាមនុស្ស ដើម្បីណែនាំឲ្យមនុស្សលោកទាំងអស់ធ្វើដំណើរតាមសមត្ថភាព ដោយធ្វើដំណើរយ៉ាងពិសេសរួមជាមួយព្រះជាម្ចាស់ ដើម្បីរកឃើញពន្លឺនៃព្រះយេស៊ូមានព្រះជន្មរស់ឡើវិញ និងរកឃើញជីវិតអស់កាលជានិច្ច។

បងប្អូនជាទីស្រលាញ់ ពេលនេះយើងអរព្រះគុណព្រះជាម្ចាស់ សូមព្រះអង្គប្រទានពរឲ្យយើង ប្រទានពរឲ្យគ្រួសារយើង ប្រទានពរឲ្យសង្គមរបស់យើងដើម្បីរួមគ្នាយើងកសាងជីវិតថ្មី សង្គមថ្មី តាមគំរោងការរបស់ព្រះជាម្ចាស់។ យើងអរព្រះគុណព្រះជាម្ចាស់សម្រាប់ព្រះនាងម៉ារី ដែលបានឯកភាពធ្វើជាមាតារបស់ព្រះជាម្ចាស់ ដើម្បីណែនាំឲ្យព្រះសង្គ្រោះចាប់កំណើតជាមនុស្ស និងធ្វើដំណើរជាមួយយើងប្រចាំថ្ងៃ។ អាម៉ែន៕